ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខៈ ៤៥៩៨ ប្រក

រដ្ឋបាលខេត្តកំពង់ធំ
ចូល លេខៈ ......
ថ្ងៃទី ...... ម៉ោង ......
បញ្ជូនទៅ: ......

# ប្រកាស

## ស្តីពី

## ការប្រឡងជ្រើសរើសបេក្ខជនឲ្យចូលបម្រើការងារនៅក្នុង ក្របខ័ណ្ឌមន្រ្តីពន្ធនាគារ ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៧

## ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្រ្តីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ស្តីពីការលើកលែងលក្ខខណ្ឌអាយុនិងការកំណត់អាយុបេក្ខជនចូលរួមប្រឡងប្រជែងជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល
- យោងលិខិតលេខ ៤៨៧ សជណ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្រ្តី

## សម្រេច

### ប្រការ ១.—

បើកឲ្យមានការប្រឡងប្រជែងជ្រើសរើសបេក្ខជនជា សិស្ស-និស្សិត ឲ្យចូលបម្រើការងារក្នុង ក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ **ចំនួន ៣៥០ នាក់** សម្រាប់ឆ្នាំ២០១៧ ដើម្បីចាត់ឲ្យទៅបម្រើការងារនៅមណ្ឌលអប់រំកែប្រែ និងពន្ធនាគារខេត្ត ដូចខាងក្រោម ៖

| ល-រ | អង្គភាព | ចំនួនក្របខ័ណ្ឌជ្រើសរើស | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | |
| **ក-** | **មណ្ឌលអប់រំកែប្រែ** | **១៧០** | **៣៥** | **២០៥** | |
| ១ | មណ្ឌលអប់រំកែប្រែទី ១ | ៤៣ | ០២ | ៤៥ | |
| ២ | មណ្ឌលអប់រំកែប្រែទី ២ | ១០ | ៣០ | ៤០ | |

| | | | | |
|---|---|---|---|---|
| ៣ | មណ្ឌលអប់រំកែប្រែទី ៣ | ១៧ | ០៣ | ២០ |
| ៤ | មណ្ឌលអប់រំកែប្រែទី ៤ | ១០០ | ០០ | ១០០ |
| **ខ-** | **ពន្ធនាគារខេត្ត** | **១២៤** | **២១** | **១៤៥** |
| ៥ | ពន្ធនាគារខេត្តកណ្ដាល | ៣១ | ០៤ | ៣៥ |
| ៦ | ពន្ធនាគារខេត្តកំពង់ចាម | ០៨ | ០២ | ១០ |
| ៧ | ពន្ធនាគារខេត្តបាត់ដំបង | ២៦ | ០៤ | ៣០ |
| ៨ | ពន្ធនាគារខេត្តបន្ទាយមានជ័យ | ៣៥ | ០៥ | ៤០ |
| ៩ | ពន្ធនាគារខេត្តសៀមរាប | ២៤ | ០៦ | ៣០ |
| | **សរុប** | **២៩៤** | **៥៦** | **៣៥០** |

## ប្រការ ២ .—

បេក្ខជនទាំងពីរភេទដែលមានសិទ្ធិសុំចុះឈ្មោះប្រឡងប្រជែងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

**ក-លក្ខខណ្ឌនៃការជ្រើសរើស៖**

១- មានសញ្ជាតិខ្មែរ

២- មានកាយសម្បទាគ្រប់គ្រាន់ មានសុខភាពល្អ។ បេក្ខជនទាំងពីរភេទត្រូវមានកំពស់ចាប់ពី **១.៦៥ ម ឡើង សម្រាប់បុរស និងមានកំពស់ចាប់ពី ១.៥៥ ម ឡើងសម្រាប់នារី ។**

៣- មិនប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី និងសិទ្ធិជាពលរដ្ឋ។

៤- បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ញាបត្រយ៉ាងទាបបំផុត មធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល។

៥- ត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយមិនលើសពី ២៥ ឆ្នាំ។ ការកម្រិតអាយុត្រូវបានរំកិលពី ២៥ ឆ្នាំ ដល់ ៣៥ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬសមមូល និង ៤០ ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល។ បេក្ខជនដែលមានកម្រិតបណ្ដុះបណ្ដាលចាប់ពីសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ។

**ខ-សំណុំលិខិតដែលត្រូវបំពេញរួមមាន៖**

១- ពាក្យសុំចុះឈ្មោះប្រឡង........................................ ចំនួន ០១ ច្បាប់

២- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬលិខិតបញ្ជាក់ការសិក្សា ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ........................................ ចំនួន ០១ ច្បាប់

៣- ជីវប្រវត្តិមានបិទរូបថត ៤x៦ ........................................ ចំនួន ០១ ច្បាប់

៤- កិច្ចសន្យា........................................ ចំនួន ០១ ច្បាប់

៥- រូបថត ៤x៦........................................ ចំនួន ០៣សន្លឹក

៦- បង្កាន់ដៃទទួលពាក្យប្រឡង........................................ ចំនួន ០១ ច្បាប់

៧- សលាកប័ត្រឯកត្តជន........................................ ចំនួន ០១ ច្បាប់

៨- សេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត........................................ ចំនួន ០១ ច្បាប់

៩- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ (ច្បាប់ថតចម្លង)........................................ ចំនួន ០១ ច្បាប់

១០- លិខិតបញ្ជាក់កិរិយាមាយាទរបស់សាមីខ្លួន ចេញដោយអាជ្ញាធរមូលដ្ឋាន ........................................ ចំនួន ០១ ច្បាប់

**ប្រការ ៣ .—**

**វិញ្ញាសា និងថេរវេលា នៃការប្រឡងជ្រើសរើស ៖**

១. ចំណេះដឹងទូទៅ ចំណេះដឹងលើវិស័យពន្ធនាគារ និងគណិតវិទ្យា រយៈពេល ០១ម៉ោង ៣០ នាទី
(កម្មវិធីសិក្សាថ្នាក់ទី ១០ ដល់ ថ្នាក់ទី ១២)

២. តែងសេចក្តី ឬការសរសេរលិខិតរដ្ឋបាល ................................ រយៈពេល ០១ ម៉ោង ៣០នាទី
(តែងសេចក្តី : កម្មវិធីសិក្សាថ្នាក់ទី ១០ ដល់ ថ្នាក់ទី ១២)។

**ប្រការ ៤ .—**

បេក្ខជនត្រូវរកពាក្យសុំចុះឈ្មោះប្រឡង និងត្រូវដាក់ពាក្យប្រឡងនៅតាមទីកន្លែងនីមួយៗដែលបានកំណត់ដូចខាងក្រោម៖

- នាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល : សម្រាប់បេក្ខជនដែលដាក់ពាក្យប្រឡងចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ នៅមណ្ឌលអប់រំកែប្រែទី ១ និងមណ្ឌលអប់រំកែប្រែទី ២។
- សាលាខេត្តទាំង ៧ **(ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តត្បូងឃ្មុំ និងខេត្តពោធិ៍សាត់)** : សម្រាប់បេក្ខជនដែលដាក់ពាក្យប្រឡងចូលបម្រើការងារនៅពន្ធនាគារខេត្តដែលជ្រើសរើស។ ដោយឡែក ចំពោះបេក្ខជនដែលដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទី ៣ ត្រូវទៅរកពាក្យសុំចុះឈ្មោះប្រឡង និងដាក់ពាក្យប្រឡងនៅសាលាខេត្តត្បូងឃ្មុំ និងបេក្ខជនដែលដាក់ពាក្យប្រលងចូលបម្រើការងារ នៅមណ្ឌលអប់រំកែប្រែទី ៤ ត្រូវទៅរកពាក្យសុំចុះឈ្មោះប្រឡង និងដាក់ពាក្យប្រឡងនៅសាលាខេត្តពោធិ៍សាត់។

**មណ្ឌលប្រឡង កាលបរិច្ឆេទទទួលពាក្យប្រឡង និងកាលបរិច្ឆេទប្រឡង :**

ការប្រឡងជ្រើសរើសមន្ត្រីពន្ធនាគារ ត្រូវបានកំណត់ឲ្យមាន ៨ មណ្ឌលប្រឡង ស្ថិតនៅរាជធានីភ្នំពេញ និងតាមខេត្តទាំង ៧ ខាងលើ។ សម្រាប់បេក្ខជនដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទាំង ៤ មណ្ឌលប្រឡងត្រូវបានកំណត់ដូចខាងក្រោម៖

- មណ្ឌលប្រឡងរាជធានីភ្នំពេញ សម្រាប់បេក្ខជនដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទី ១ និងមណ្ឌលអប់រំកែប្រែទី ២
- មណ្ឌលប្រឡងខេត្តត្បូងឃ្មុំ សម្រាប់បេក្ខជនដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទី ៣
- មណ្ឌលប្រឡងខេត្តពោធិ៍សាត់ សម្រាប់បេក្ខជនដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទី ៤ ។

កាលបរិច្ឆេទទទួលពាក្យប្រឡងចាប់ពីថ្ងៃជូនដំណឹង រហូតដល់ថ្ងៃ **សុក្រ ទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧** ។

កាលបរិច្ឆេទប្រឡងនៅថ្ងៃ **អាទិត្យ ទី១៧ ខែធ្នូ ឆ្នាំ ២០១៧** ។

**ប្រការ ៥ .—**

ការប្រឡងជ្រើសរើសបេក្ខជនឲ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ត្រូវដឹកនាំ និងចាត់ចែងដោយគណៈកម្មការកណ្តាលរៀបចំការប្រឡង និងគណៈកម្មការរៀបចំការប្រឡងខេត្ត ដែលសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

គណៈកម្មការកណ្តាលរៀបចំការប្រឡង និងគណៈកម្មការរៀបចំការប្រឡងខេត្ត មានសិទ្ធិរៀងៗខ្លួន ក្នុងការប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ និងត្រារដ្ឋបាលរាជធានីខេត្ត ។

**ប្រការ ៦ .—**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តពាក់ព័ន្ធ ប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

***កន្លែងទទួល:***
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងមុខងារសាធារណៈ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  *(ដើម្បីជូនជ្រាប)*
- *ដូចប្រការ ៦ (ដើម្បីអនុវត្ត)*
- *ឯកសារ-កាលប្បវត្តិ*

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ: ១៧៤៥ សជណ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពង់ធំ

ចូល លេខ: ......

ថ្ងៃទី...... ម៉ោង......

បញ្ជូនទៅ:......

# សេចក្តីជូនដំណឹង

ក្រសួងមហាផ្ទៃ សូមជូនដំណឹងដល់សិស្ស-និស្សិត ដែលមានបំណងចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ឲ្យបានជ្រាបថា ក្រសួងមហាផ្ទៃ សម្រេចបើកឲ្យមានការប្រឡងជ្រើសរើសសិស្ស-និស្សិត បញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ **ចំនួន ៣៥០ នាក់** សម្រាប់ឆ្នាំ២០១៧ ដើម្បីចាត់ឲ្យទៅបម្រើការងារនៅមណ្ឌលអប់រំកែប្រែ និងនៅពន្ធនាគារខេត្ត ដូចខាងក្រោម ៖

| ល-រ | អង្គភាព | ចំនួនក្របខ័ណ្ឌជ្រើសរើស | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | |
| **ក-** | **មណ្ឌលអប់រំកែប្រែ** | **១៧០** | **៣៥** | **២០៥** | |
| ១ | មណ្ឌលអប់រំកែប្រែទី ១ | ៤៣ | ០២ | ៤៥ | |
| ២ | មណ្ឌលអប់រំកែប្រែទី ២ | ១០ | ៣០ | ៤០ | |
| ៣ | មណ្ឌលអប់រំកែប្រែទី ៣ | ១៧ | ០៣ | ២០ | |
| ៤ | មណ្ឌលអប់រំកែប្រែទី ៤ | ១០០ | ០០ | ១០០ | |
| **ខ-** | **ពន្ធនាគារខេត្ត** | **១២៤** | **២១** | **១៤៥** | |
| ៥ | ពន្ធនាគារខេត្តកណ្តាល | ៣១ | ០៤ | ៣៥ | |
| ៦ | ពន្ធនាគារខេត្តកំពង់ចាម | ០៨ | ០២ | ១០ | |
| ៧ | ពន្ធនាគារខេត្តបាត់ដំបង | ២៦ | ០៤ | ៣០ | |
| ៨ | ពន្ធនាគារខេត្តបន្ទាយមានជ័យ | ៣៥ | ០៥ | ៤០ | |
| ៩ | ពន្ធនាគារខេត្តសៀមរាប | ២៤ | ០៦ | ៣០ | |
| | **សរុប** | **២៩៤** | **៥៦** | **៣៥០** | |

## ក. ពាក្យសុំចុះឈ្មោះប្រឡង និង មណ្ឌលប្រឡង

បេក្ខជនត្រូវរកពាក្យសុំចុះឈ្មោះប្រឡង និងត្រូវដាក់ពាក្យប្រឡងនៅតាមទីកន្លែងនីមួយៗដែលបានកំណត់ដូចខាងក្រោម៖

- នាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល : សម្រាប់បេក្ខជនដែលដាក់ពាក្យប្រឡងចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធនាគារ មណ្ឌលអប់រំកែប្រែទី ១ និងមណ្ឌលអប់រំកែប្រែទី ២។
- សាលាខេត្ត **(ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តពោធិ៍សាត់ និងខេត្តត្បូងឃ្មុំ)** : សម្រាប់បេក្ខជនដែលដាក់ពាក្យប្រឡងចូលបម្រើការងារនៅពន្ធនាគារខេត្តដែលជ្រើសរើស។ ដោយឡែក ចំពោះបេក្ខជនដែលដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទី ៣ ត្រូវរកពាក្យសុំចុះឈ្មោះប្រឡង និងដាក់ពាក្យប្រឡងនៅសាលាខេត្តត្បូងឃ្មុំ និងបេក្ខជនដែលដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទី ៤ ត្រូវរកពាក្យសុំចុះឈ្មោះប្រឡង និងដាក់ពាក្យប្រឡងនៅសាលាខេត្តពោធិ៍សាត់។

ការប្រឡងជ្រើសរើសក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ត្រូវបានកំណត់ឲ្យមាន ៨ មណ្ឌលប្រឡង ស្ថិតនៅរាជធានីភ្នំពេញ និងតាមខេត្តទាំង ៧ ខាងលើ ។ សម្រាប់បេក្ខជនដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទាំង ៤ មណ្ឌលប្រឡងត្រូវបានកំណត់ដូចខាងក្រោម៖

- មណ្ឌលប្រឡងរាជធានីភ្នំពេញ សម្រាប់បេក្ខជនដាក់ពាក្យប្រឡងចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធនាគារ មណ្ឌលអប់រំកែប្រែទី ១ និងមណ្ឌលអប់រំកែប្រែទី ២
- មណ្ឌលប្រឡងខេត្តត្បូងឃ្មុំ សម្រាប់បេក្ខជនដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទី ៣
- មណ្ឌលប្រឡងខេត្តពោធិ៍សាត់ សម្រាប់បេក្ខជនដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទី ៤ ។

## ៦. កាលបរិច្ឆេទនៃការទទួលពាក្យ និងការប្រឡង

កាលបរិច្ឆេទទទួលពាក្យប្រឡងគឺនៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹង រហូតដល់ **នាថ្ងៃសុក្រ ទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ម៉ោង ១៧ : ០០ នាទី ជាកាលបរិច្ឆេទកំណត់ចុងក្រោយ** ។

កាលបរិច្ឆេទប្រឡង គឺនៅថ្ងៃ **អាទិត្យ ទី១៧ ខែធ្នូ ឆ្នាំ២០១៧** ។

ព័ត៌មានលំអិតផ្សេងៗទៀត សូមអញ្ជើញទាក់ទងផ្ទាល់នៅតាមការិយាល័យទទួលពាក្យសុំចុះឈ្មោះប្រឡងនៅតាមទីកន្លែងដែលបានកំណត់ នៅរៀងរាល់ម៉ោងធ្វើការ ។/.

**រាជធានីភ្នំពេញ ថ្ងៃទី** ២៧ **ខែ** កញ្ញា **ឆ្នាំ២០១៧**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងព័ត៌មាន
- ក្រសួងមុខងារសាធារណៈ
  (ដើម្បីជូនជ្រាប)
- គ្រប់សាលាខេត្តពាក់ព័ន្ធ
  (ដើម្បីផ្សព្វផ្សាយ និងអនុវត្តន៍)
- ឯកសារ - កាលប្បវត្តិ